# ព័ត៌មានសម្រាប់ មាតាបិតា ឬអាណាព្យាបាល

ការប្រឡង យីស្តូន (Keystone) សម្រាប់រដ្ឋផិនស៊ីលវេញ៉ា

## តើការប្រឡង យីស្តូន ជាអ្វី?

**ការប្រឡង យីស្តូន** គឺជាការវាយតម្លៃនៅពេលរៀនចប់មុខវិទ្យា ដែលបានរៀបចំឡើងដើម្បីវាយតម្លៃការស្ទាត់ជំនាញនៃមុខវិទ្យាសិក្សា។ ចាប់ផ្តើមជាមួយថ្នាក់ក្នុងឆ្នាំ២០១៧ សិស្សានុសិស្សត្រូវបង្ហាញឲ្យឃើញនូវការស្ទាត់ជំនាញផ្នែក ពិជគណិតកម្រិត១ អក្សរសាស្ត្រ និង ជីវវិទ្យា (Algebra 1, Literature, and Biology) នៃការប្រឡង យីស្តូន ទើបអាចបញ្ចប់ការសិក្សាបាន។ គេនឹងផ្តល់ឲ្យសិស្សានុសិស្សនូវឱកាសជាច្រើន ដើម្បីប្រឡង យីស្តូន ក្នុងរយៈពេលដែលពួកគេរៀននៅវិទ្យាល័យ។

## តើអ្នកណានឹងចូលរួមក្នុងការប្រឡង យីស្តូន នេះ?

ចាប់ផ្តើមនៅឆ្នាំ ២០១២-២០១៣ ការប្រឡង ពិជគណិតកម្រិត១ អក្សរសាស្ត្រ និងជីវវិទ្យា របស់ យីស្តូន នឹងជំនួសការប្រឡងតាមប្រព័ន្ធវាយតម្លៃសាលារបស់រដ្ឋផិនស៊ីលវេញ៉ា (PSSA) ថ្នាក់ទី១១ ផ្នែក គណិតវិទ្យា ការអាន និងវិទ្យាសាស្ត្រ ដែលជាគោលបំណងនៃការទទួលខុសត្រូវរបស់ សិស្ស អ្នកអប់រំ និង សាលា។ សិស្សានុសិស្សត្រូវប្រឡង យីស្តូន នៅពេល ឬជិតដល់ពេលរៀនចប់មុខវិទ្យា ដែលទាក់ទងនឹងការប្រឡង យីស្តូន។ លទ្ធផលរបស់សិស្សត្រូវ គេរក្សាទុករហូតដល់ឆ្នាំទី៣នៅវិទ្យាល័យ សម្រាប់គោលបំណងនៃការទទួលខុសត្រូវ ហើយរហូតដល់ឆ្នាំទី៤នៅវិទ្យាល័យ សម្រាប់គោលបំណងនៃការបញ្ចប់ការសិក្សា។ សិស្សានុសិស្សខ្លះដែលទើបបានរៀនចប់មុខវិទ្យាដែលទាក់ទងនឹងការប្រឡង យីស្តូន ប៉ុន្តែមិនបានប្រឡង យីស្តូន ក៏នឹងចូលរួម សម្រាប់គោលបំណងនៃការទទួលខុសត្រូវនេះដែរ។ ជាបន្ថែមទៀត សិស្សានុសិស្សដែលប្រឡង យីស្តូន ហើយមិនបានពិន្ទុ ស្ទាត់ជំនាញ/Proficient អាចប្រឡងជាថ្មីម្តងទៀត។

## តើនឹងមានការប្រឡងនៅពេលណា?

**ការប្រឡង** យីស្តូន នឹងប្រព្រឹត្តទៅបីដងក្នុងមួយឆ្នាំ—រដូវរងា រដូវផ្ការីក និងរដូវក្តៅ។ ថ្ងៃខែប្រឡងច្បាស់លាស់នឹងផ្សាយជូនដោយ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា។

## តើអ្នកណាជាអ្នកសម្រេចថាតើត្រូវយកការប្រឡង យីស្តូន មួយណាមកថ្លឹងថ្លែង?

ក្រុមអ្នកអប់រំដែលមកពីតំបន់ផ្សេងៗក្នុងរដ្ឋផិនស៊ីលវេញ៉ា បានជ្រើសរើសមុខវិទ្យាដែលការប្រឡង យីស្តូន យកជាមូលដ្ឋាន។ ក្រុមទាំងនេះមាន គ្រូ អ្នកគ្រប់គ្រង នាយកផ្នែកកម្មវិធីសិក្សា និង អ្នកឯកទេសផ្នែកមហាវិទ្យាល័យ។ ក្រុមទាំងនេះក៏បាន ពិនិត្យដោយហ្មត់ចត់ឡើងវិញ កែសម្រួល និងបានយល់ព្រមនូវរាល់សំណួរសម្រាប់ការប្រឡង។

## តើគេវាយតម្លៃអ្វី លើការប្រឡង យីស្តូន?

រដ្ឋផិនស៊ីលវេញ៉ាបានអនុវត្តតាមខ្នាតគំរូសំខាន់ៗទូទៅ ខ្នាតគំរូដែលស្របតាមគោលបំណង ដើម្បីឲ្យមានជោគជ័យនៅ មហាវិទ្យាល័យ និងកន្លែងធ្វើការ។ យីស្តូន បានរៀបចំឡើងដើម្បីស្ទង់មើលខ្នាតគំរូទាំងនេះ។

## តើមានរយៈពេលប៉ុន្មាន សម្រាប់ការប្រឡង យីស្តូន?

គ្មានពេលកំណត់ សម្រាប់ឲ្យសិស្សប្រឡង យីស្តូន ឲ្យចប់សព្វគ្រប់នោះទេ។ ការប្រឡង យីស្តូន នីមួយៗ ត្រូវចំណាយពេលពី ២ ទៅ ៣ ម៉ោង សម្រាប់សិស្សជាទូទៅធ្វើឲ្យចប់។ ការប្រឡងនីមួយៗមានពីរផ្នែក ហើយមួយផ្នែកៗ ( ឬរយៈពេលប្រឡង) នៃការប្រឡង យីស្តូន ត្រូវចំណាយពេលពីមួយម៉ោង ទៅមួយម៉ោងកន្លះ ទើបធ្វើរួច។ ក្រសួងអាចឲ្យសិស្សប្រឡង យីស្តូន រយៈពេលពីរថ្ងៃ ឬចែកជាពេលព្រឹក និងពេលថ្ងៃរសៀល នៅថ្ងៃតែមួយ។

## តើការប្រឡង យីស្តូន មានប៉ុន្មានយ៉ាង?

ការប្រឡង យីស្តូន អាចធ្វើឡើងតាមអ៊ិនធ័រណិត និងតាមក្រដាស/ខ្មៅដៃ។ ក្រសួងអប់រំនឹងសម្រេចថាតើត្រូវប្រឡងតាមអ៊ិនធ័រណិត តាមក្រដាស/ខ្មៅដៃ ឬទាំងពីរយ៉ាង នៅតាមកន្លែងនីមួយៗ។ ការប្រឡងឡើងវិញក៏អាចធ្វើតាមអ៊ិនធ័រណិត ឬតាមក្រដាស/ខ្មៅដៃ បានដែរ។

## តើសិស្សានុសិស្សនឹងមានឱកាសដើម្បីសាកល្បងមើលការប្រឡងតាម អ៊ិនធ័រណិត មុនពេលប្រឡង យីស្តូន តាម អ៊ិនធ័រណិតដែរឬទេ?

គេកំពុងរៀបចំកម្មវិធីសម្រាប់ជួយបង្រៀន និងហ្វឹកហ្វឺន តាមអ៊ិនធ័រណិត សម្រាប់ការប្រឡង យីស្តូន។ ការជួយបង្រៀបតាមអ៊ិនធ័រណិត សម្រាប់ការវាយតម្លៃសិស្ស របស់រដ្ឋផិនស៊ីលវេញ៉ា ប្រើ រូបភាពចលនា និង សម្លេង ដើម្បីបង្ហាញរូបភាព និងពាក្យពេចន៍ នៃការពិពណ៌នា អំពីផ្នែកសំខាន់ៗ នៃប្រព័ន្ធវាយតម្លៃតាមអ៊ិនធ័រណិតរបស់រដ្ឋផិនស៊ិលវេញ៉ា។ សិស្សអាចមើលការជួយបង្រៀននេះសារឡើងវិញ បានតាមចិត្ត។ ការហ្វឹកហ្វឺនតាមអ៊ិនធ័រណិត (OTT) ផ្តល់នូវបទពិសោធន៍ថ្មី ក្នុងការប្រើ កម្មវិធីកុំព្យូទ័រសម្រាប់ការវាយតម្លៃតាមអ៊ិនធ័រណិតរបស់រដ្ឋផិនស៊ីលវេញ៉ា ដែលអនុញ្ញាតឲ្យសិស្សានុសិស្សកត់សម្គាល់ និងសាកល្បងនូវផ្នែកសំខាន់ៗនៃកម្មវិធីកុំព្យូទ័រសម្រាប់ការវាយតម្លៃតាមអ៊ិនធ័រណិតរបស់រដ្ឋផិនស៊ីលវេញ៉ា មុនពេលគេធ្វើការវាយតម្លៃពិតប្រាកដ។ នៅក្នុងការហ្វឹកហ្វឺនតាមអ៊ិនធ័រណិត សិស្សានុសិស្សក៏មានឱកាសហាត់សរសេរចម្លើយតាមរបៀបការអធិប្បាយ គូរក្រាហ្វ និងបញ្ចូលសមីការ តាមការប្រើសម្ភារៈបង្កើតសមីការ។ ការប្រឡងតាមអ៊ិនធ័រណិតក៏មាន ផ្នែក«ជំនួយ/Help» សម្រាប់សិស្សនៅពេលប្រឡង។

### **តើមានសំណួរប្រភេទណាខ្លះនៅក្នុងការប្រឡង ឃីស្តូន?**

ការប្រឡង ឃីស្តូន មានចម្លើយសម្រាប់ជ្រើសរើស និង ចម្លើយតាមការពន្យល់ច្បាស់លាស់ ឬ ចម្លើយតាមគំនិតរបស់ខ្លួន។ សម្រាប់ការប្រឡង ឃីស្តូន នីមួយៗ ប្រហែលជា ៦០% ទៅ ៧៥% នៃពិន្ទុសរុប បានមកពីសំណួរដែលមានចម្លើយសម្រាប់ជ្រើសរើស ហើយ ២៥% ទៅ ៤០% នៃពិន្ទុសរុប បានមកពីចម្លើយតាមការពន្យល់ច្បាស់លាស់។

### **តើគេឲ្យពិន្ទុដល់ ការសរសេរចម្លើយ សម្រាប់ចម្លើយតាមការពន្យល់ច្បាស់លាស់ យ៉ាងដូចម្តេច?**

ការសរសេរចម្លើយ សម្រាប់ចម្លើយតាមការពន្យល់ច្បាស់លាស់ ត្រូវបានឲ្យពិន្ទុដោយអ្នកវាយតម្លៃដែលបានហ្វឹកហ្វឺនក្នុងការអនុវត្តន៍ប្រព័ន្ធឲ្យពិន្ទុ ដែលបានសម្រេចជាមុន។ ពិន្ទុយោងទៅលើអត្ថន័យតែប៉ុណ្ណោះ។ ការប្រកបអក្សរ និងវិធីប្រើវណ្ណយុត្ត មិនរាប់បញ្ចូលជាផ្នែកនៃវិធីឲ្យពិន្ទុទេ។ ភាគច្រើន សំណួរដែលត្រូវការចម្លើយតាមការពន្យល់ច្បាស់លាស់ តម្រូវឲ្យសិស្សបង្ហាញនូវអ្វីៗដែលគេធ្វើ ឬពន្យល់ពីចម្លើយរបស់ពួកគេ។ សំណួរនៃការប្រឡង ឃីស្តូន ទាំងនេះ នឹងសុំឲ្យសិស្ស ពន្យល់ ធ្វើវិភាគ អធិប្បាយ ឬប្រៀបធៀប។ សំណួរខ្លះក៏តម្រូវឲ្យសិស្ស ធ្វើការគិតលេខ ឬ គូរក្រាហ្វ គូរប្លង់ ឬគូរអ្វីផ្សេងៗផងដែរ។

### **តើគេនឹងរាយការណ៍ពីលទ្ធផល ដោយរបៀបណា?**

គេនឹងរៀបចំពិន្ទុនៃការប្រឡង ឃីស្តូន យ៉ាងឆាប់រហ័ស ហើយផ្តល់ទៅឲ្យក្រសួង។

គេនឹងផ្ញើរបាយការណ៍នៃការប្រឡង ឃីស្តូន ទាំងអស់ របស់សិស្សម្នាក់ៗ ពីរច្បាប់ ទៅក្រសួងអប់រំ និងសាលាឆាធ័រ។ មួយច្បាប់ទៀតត្រូវផ្ញើទៅ មាតាបិតា/អាណាព្យាបាល។ សាលា/ក្រសួង នឹងរក្សាទុកមួយច្បាប់។

របាយការណ៍នៅសាលានឹងប្រើសម្រាប់កម្មវិធីសិក្សា និងការរៀបចំផែនការ។ ក្រសួងអប់រំ និង សាលាឆាធ័រ អាចផ្សព្វផ្សាយលទ្ធផលនៃការប្រឡង ឃីស្តូន សម្រាប់សាលានីមួយ។ រដ្ឋក៏នឹងបញ្ចេញទិន្នន័យនៃការប្រឡង សម្រាប់សាលានីមួយៗដែរ។

### **តើមាតាបិតាអាចមើលវិញ្ញាសានៃការប្រឡង ឃីស្តូន បានឬទេ?**

មាតាបិតា និងអាណាព្យាបាល អាចពិនិត្យមើលវិញ្ញាសានៃការប្រឡង ឃីស្តូន បាន បើសិនជាគាត់ជឿថា វាអាចមានការប៉ះពាល់ដល់ជំនឿសាសនារបស់គាត់ ដោយធ្វើការរៀបចំជាមួយអ្នកចាត់ចែងការប្រឡងនៅសាលា នៅពេលដែលវិញ្ញាសានៃការប្រឡងមកដល់សាលា។ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្នុងការរក្សាការសម្ងាត់ ហើយគេមិនអនុញ្ញាតឲ្យចម្លងវិញ្ញាសានៃការប្រឡង ឃីស្តូន ឬយកកំណត់ត្រាអំពីសំណួរនៃការប្រឡង ចេញពីសាលាទេ។

បើសិនជា ក្រោយពេលពិនិត្យវិញ្ញាសានៃការប្រឡង ឃីស្តូន រួចហើយ មាតាបិតា ឬអាណាព្យាបាល មិនចង់ឲ្យកូនចូលរួមក្នុងការប្រឡងណាមួយ ឬការប្រឡងទាំងអស់ ដោយសារមានការប៉ះពាល់ដល់ជំនឿសាសនារបស់គាត់ គាត់អាចសរសេរលិខិតទៅ អគ្គនាយកនៃក្រសួងអប់រំ ឬនាយកផ្នែកសិក្សាធិការនៃសាលាឆាធ័រ មុននឹងចាប់ផ្តើមការប្រឡង ដើម្បីស្នើសុំការលើកលែងការប្រឡងឲ្យកូនរបស់គាត់។

### **តើការវាយតម្លៃដែលយោងទៅលើកិច្ចការដែលដាក់ឲ្យសិស្សធ្វើ (Project Based Assessments (PBAs)) ជាអ្វី?**

PBAs គឺជាការវាយតម្លៃតាមអ៊ិនធ័រណិតដែលស្របតាមបែបបទនៃការប្រឡង ឃីស្តូន ។ ការវាយតម្លៃទាំងនេះគឺជាវិធីផ្សេងទៀត ដែលធ្វើឡើងដើម្បីឲ្យត្រូវតាមតម្រូវការ នៃការបញ្ចប់ការសិក្សារបស់រដ្ឋ ចាប់ផ្តើមធ្វើជាមួយថ្នាក់ដែលបញ្ចប់ការសិក្សានៅឆ្នាំ២០១៧។ ក្រោយពីបានប្រឡង ឃីស្តូន ពីរដង មិនបានជោគជ័យ សិស្សានុសិស្សអាចជ្រើសយក PBAs ចំពោះការប្រឡង ឃីស្តូន ដែលពួកគេប្រឡងធ្លាក់។ PBAs មានសុវត្ថិភាព ការធ្វើតាមអ៊ិនធ័រណិតនៅសាលា ដែលមានការមើលខុសត្រូវ និង ត្រូវបញ្ជូនទៅឲ្យអ្នកវាយតម្លៃរបស់រដ្ឋ ក្រោយពេលធ្វើចប់។ ដើម្បីជ្រាបព័ត៌មានបន្ថែម សូមមើលក្នុង វ៉ិបសៃ http://www.pdesas.org/module/assessment/About.aspx

ការជ្រើសរើសមិនចូលរួមដោយសារសាសនា គឺសម្រាប់តែការប្រឡង ឃីស្តូន តែប៉ុណ្ណោះ។ មិនមែនសម្រាប់ PBAs ទេ។ សិស្សានុសិស្សដែលរៀនចប់ពីវិទ្យាល័យក្នុងឆ្នាំ២០១៧ និង ក្រោយឆ្នាំនេះ ដែលបានជ្រើសរើសមិនចូលរួមក្នុងការប្រឡង ឃីស្តូន ត្រូវតែបំពេញ និងបង្ហាញនូវការស្ទាត់ជំនាញក្នុង PBAs ទើបអាចបញ្ចប់ការសិក្សាបាន។

***ដើម្បីជ្រាបព័ត៌មានបន្ថែមអំពី ការប្រឡង Keystone សូមមើល SAS វ៉ិបសៃ www.pdesas.org ឬទាក់ទងទៅក្រសួងអប់រំរបស់លោកអ្នក។***

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវ៉ិបសៃ៖ www.philasd.org/language/khmer